**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៥១ សសរ**

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការចំរុះ ដើម្បីសិក្សាបន្ថែមអំពីរបៀបចាក់លុបផ្ទៃដីបឹងស្លាយ**

**ខេត្តកំពង់ចាម**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់

**សម្រេច**

**ប្រការ ១**: បង្កើតគណៈកម្មការចំរុះ ដើម្បីសិក្សាអំពីរបៀបចាក់លុបផ្ទៃដីបឹងស្លាយខេត្តកំពង់ចាម ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ឹម ឈុនលឹម** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២-ឯកឧត្តម **ជា សុផារ៉ា** | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៣-ឯកឧត្តម **ហ៊ុន ណេង** | អភិបាលខេត្តកំពង់ចាម | អនុប្រធានអចិន្ត្រៃយ៍ |

៤-ឯកឧត្តម **ម៉ុន អ៊ុយ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
៥-ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៦-ឯកឧត្តម **អ៊ិត ប្រាំង** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក
៧-ឯកឧត្តម **សំ សារិត** រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម សមាជិក
៨-ឯកឧត្តម **ស៊ួន ហោង** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
៩-ឯកឧត្តម **នូ តៀង** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
១០-ឯកឧត្តម **ឆា ជុម** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

**ប្រការ ២** : គណៈកម្មការចំរុះនេះ មានភារកិច្ចសិក្សាបន្ថែមអំពីរបៀបចាក់លុបផ្ទៃដីបឹងស្លាយ ដោយធានាដោះស្រាយការបាត់ផ្លូវរងទឹកភ្លៀង ទីតាំងប្រភពដីដែលត្រូវបូមចាក់លុបបឹង និងអំពីការទូទាត់សំណងដោយផ្ទាល់ ដើម្បីលើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច ។

**ប្រការ ៣** : អនុប្រធាន និងសមាជិកគណៈកម្មការចំរុះនេះ ត្រូវចូលរួមប្រជុំ និងចូលរួមបំពេញភារកិច្ចតាមការអញ្ជើញ និងតាមការណែនាំរបស់ប្រធាន ។

**ប្រការ ៤** : គណៈកម្មការចំរុះនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្នុងករណីចាំបាច់គណៈកម្មការចំរុះនេះ អាចបង្កើតអនុគណៈកម្មការ ឬក្រុមការងារជំនាញដើម្បីជួយក្នុងកិច្ចការសិក្សាបន្ថែមនេះ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ